Khmer

# ស្តីពីការលូតលាស់របស់កូន តើលោកអ្នកមានការបារម្ភអ្វីឬទេ?

～ចំពោះឪពុកម្តាយឬអ្នកអាណាព្យាបាលដែលចិញ្ចឹមកូននៅជប៉ុន～




មជ្ឈមណ្ឌលជាតិស្តារកាយនីតិសម្បទាជនពិការ

មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់

http://www.rehab.go.jp/ddis/

# សេចក្ដីផ្ដើម

ពេលថ្មីៗនេះ ឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលជាជនបរទេស ហើយដែលចិញ្ចឹមកូននៅប្រទេសជប៉ុនកើនកាន់តែច្រើនឡើងៗ។

- អ្នកដែលមានការលំបាកក្នុងការចិញ្ចឹមកូន ដោយសារតែរស់នៅក្នុងប្រទេសដែលមានវប្បធម៌ និងទម្លាប់នៃការរស់នៅខុសគ្នា
- អ្នកដែលមានការពិបាកក្នុងការទទួលព័ត៌មានចាំបាច់ក្នុងការចិញ្ចឹមកូន ដោយសារតែបញ្ហាភាសា
- អ្នកដែលមានការបារម្ភស្ដីពីការលូតលាស់របស់កូន

កូនសៀវភៅនេះត្រូវបានបង្កើតឡើងដើម្បីឱ្យលោកអ្នកជាឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលជាជនបរទេសខាងលើនេះអាចចិញ្ចឹមកូនដោយគ្មានការបារម្ភ។

ជាពិសេស ក្នុងករណីដែលមានការបារម្ភចំពោះការលូតលាស់របស់កូន លោកអ្នកច្បាស់ជាមិនដឹងធ្វើយ៉ាងណាដើម្បីរកអ្នកពិគ្រោះ។

នៅតាមកន្លែងនីមួយៗទូទាំងប្រទេសជប៉ុន មានស្ថាប័ន(កន្លែង)ជាច្រើនដែលជួយឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលមានការបារម្ភចំពោះការលូតលាស់របស់កូន។ យើងខ្ញុំមានមោទនភាពណាស់ បើសិនជាលោកអ្នកដែលជាឪពុកម្ដាយឬអ្នកអាណាព្យាបាលដែលជាជនបរទេស ប្រើកូនសៀវភៅនេះដើម្បីងាយស្រួលរកព័ត៌មាន ឬជំនួយចាំបាច់។

មជ្ឈមណ្ឌលជាតិស្តារកាយនីតិសម្បទាជនពិការ
មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់

# មាតិកា


## ចង់ដឹងអំពីស្ថានភាពនៃការលូតលាស់របស់កូន ..... 3

ឧទាហរណ៍ តើធ្លាប់មានបញ្ហាបែបនេះឬទេ ? ..... 3

រហូតដល់អាយុ 3ឆ្នាំ ..... 3

ពីអាយុ 3 ដល់ 6ឆ្នាំ (ពេលចូលសាលាបឋមសិក្សា) ..... 4

សូមទៅទទួលការពិនិត្យសុខភាពនៅសាលាស្រុក ឃុំ ភូមិ ..... 5

ការពិនិត្យសុខភាពទារកកំពុងបំបៅ ..... 5

ការពិនិត្យសុខភាពកូនអាយុ 1ឆ្នាំកន្លះ ..... 5

ការពិនិត្យសុខភាពកូនអាយុ 3ឆ្នាំ ..... 6

ការពិនិត្យសុខភាពមុនចូលសាលា ..... 7

ការពិគ្រោះអំពីការចូលសាលា ..... 7

【ឯកសារយោង】 កន្លែងអប់រំកុមារដែលចាំបាច់មានជំនួយពិសេស(អប់រំដោយមានជំនួយពិសេស) ..... 8

## ចង់ពិគ្រោះ ..... 9

សូមទៅពិគ្រោះ ..... 9

ស្ថាប័នពិគ្រោះនៅស្រុក ឃុំ ភូមិ នៃលំនៅដ្ឋានលោកអ្នក ..... 10

## អ្វីទៅ វិបត្តិក្នុងការលូតលាស់ ? ..... 11

ច្បាប់ស្តីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ ..... 12

ស្តីពីមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ ..... 12

## ចង់ទៅពេទ្យ ..... 13

ស្តីពីមន្ទីរពេទ្យ, ការពិនិត្យ, វិធីព្យាបាលពិសេស ..... 13

បើសិនជាគ្រូពេទ្យថា កូនមានវិបត្តិក្នុងការលូតលាស់ ..... 13

ការប្រើថ្នាំ ដើម្បីឱ្យមានជីវភាពស្រួលបួល ..... 14

## ចង់ដឹងអំពីសៀវភៅជនពិការ ..... 15

ឧទាហរណ៍នៃសេវាកម្មដែលអាចទទួលបាន ..... 15

សៀវភៅព្យាបាលថែទាំ ..... 16

សៀវភៅសុខភាពសុខុមាលភាពជនពិការផ្លូវចិត្ត ..... 16

## ចង់បានព័ត៌មានដែលមានប្រយោជន៍សម្រាប់ជីវភាពរស់នៅ (ព័ត៌មានយោង) ..... 17

សេវាកម្មពិគ្រោះជាភាសាបរទេស ..... 17

Apps បកប្រែ ..... 18

ព័ត៌មានស្តីពីការអប់រំតាមសាលា, ព័ត៌មានស្តីពីវិបត្តិក្នុងការលូតលាស់ ..... 19

កម្រងពាក្យខ្មែរជប៉ុន ..... 20

# ឧទាហរណ៍ តើធ្លាប់មានបញ្ហាបែបនេះឬទេ?

## រហូតដល់អាយុ 3ឆ្នាំ

·ការលូតលាស់នៃភាសាមានការយឺតយ៉ាវ។
·ភ្លេចអស់នូវពាក្យដែលបាននិយាយ។
·មានការពិបាកនឹងប្រាស្រ័យទាក់ទង ឬប្រាស្រ័យទាក់ទងតែពីសាមីតែម្ខាង មិនមានការឆ្លងឆ្លើយគ្នា។
·លេងតែល្បែងមួយមុខដដែលៗរាល់ពេល។



·មើលភ្នែកមិនចំ ឬពិបាកចំ។
·មិនចូលចិត្តឱ្យគេឱប។
·ទឹកមុខមិនប្រែប្រួល
·ហៅឈ្មោះក៏មិនបែរមករកទេ។



·មានរបស់ ឬកន្លែងដែលមិនចូលចិត្តខ្លាំង។
·ចូលចិត្តតែរបស់ដដែលៗ ឬធ្វើអ្វីដដែលៗ។

·សមត្ថភាពធ្វើចលនាលូតលាស់យឺត ដូចជាមិនសូវរឹងចេះអង្គុយយឺត ចេះដើរយឺត។
·សាច់ដុំទន់ ហើយមានការពិបាកនឹងរក្សាឥរិយាបថដដែលឱ្យបានយូរ។



·អារម្មណ៍មិននឹង។
·មិននៅនឹងមួយកន្លែង ត្រូវតាមមើលរហូត។
·ខ្វះការផ្តោតអារម្មណ៍ខ្លាំង ។

·អ្វីៗច្រើនតែមិនត្រូវចិត្ត មិនស្ងប់ចិត្ត។
·ធ្វើអំពើដែលអាចឱ្យរបួសខ្លួនឯងជាច្រើនដង។
(វាយក្បាលខ្លួនឯង, ខាំដៃខ្លួនឯង ជាដើម)



·ពេលយប់ យំរហូតមិនបាត់ រាប់ខែហើយ។
·មិនគេងថ្ងៃ។ គេងមិនលក់។
·របស់ចូលចិត្តញ៉ាំ និងមិនចូលចិត្តញ៉ាំច្រើនពេក។



·មិនបែរមុខទៅកន្លែងដែលមានសម្លេងទេ។
·ចាប់អារម្មណ៍ខ្លាំងជ្រុលទៅលើសម្លេង (បិទត្រចៀកខ្លួនឯង)។



# ពីអាយុ 3 ដល់ 6ឆ្នាំ (ពេលចូលសាលាបឋមសិក្សា)



- គ្មានចំណាប់អារម្មណ៍ទៅលើកូនដទៃទេ។ មិនចេះលេងជាមួយក្មេងៗដូចគ្នា។
- ចំណូលចិត្តមានការលំអៀង(ពណ៌ ពាណិជ្ជសញ្ញា សញ្ញា អក្សរ ឬលេខជាក់លាក់ណាមួយ ជាដើម)។
- សួរសំណួរដដែលៗ ឬនិយាយតែរឿងដដែលៗ។
- ច្រើនតែនៅម្នាក់ឯង។



- មិនខ្វល់ខ្វាយចំពោះវិន័យ ឬការសន្យា។
- ចាប់ផ្តើមនិយាយខ្លួនឯង ហើយឈប់តាមចិត្តខ្លួនឯង។
- មានការពិបាកលេងនឹងមិត្តភក្តិ។ ចេះតែរករឿងគេ។
- ធ្វើចលនា មិននឹងនរ។
- ទៅកន្លែងដែលចូលចិត្តដោយខ្លួនឯង។
- មិនស្តាប់ការពន្យល់ដល់ចប់ទេ។

- មិនយល់នូវខ្លឹមសារដែលខ្លួនស្តាប់។
- មិនចេះអក្សរ ឬលេខ។
- ចេះអ្វីមួយចេះខ្លាំង មិនចេះអ្វី គឺមិនចេះតែម្តង។







- ពេលធ្វើអ្វីមួយជាមួយអ្នកផ្សេង មិនអាចធ្វើសកម្មភាពដូចគេដូចឯងទេ។
- ត្រៀម ឬរៀបចំអ្វីមួយ ប្រើពេលវេលាច្រើន។
- មិនចេះគូររូប ឬប្រើកន្ត្រៃ។
- មិនចង់ឱ្យគេប៉ះពាល់ខ្លួនប្រាណ។
- មានការពិបាកនឹងបង្រៀនឱ្យចេះរស់នៅ ដូចជាទៅបង្គន់ ឬផ្លាស់ខោអាវ ជាដើម។

## ពេលដែលមានកូនមានបញ្ហាបែបនេះ មានការបារម្ភណាស់ .....

ក្រុមគ្រួសារមានការធុញថប់យ៉ាងខ្លាំង ដោយគិតថា "កូននោះមានបញ្ហា" ឬ "របៀបចិញ្ចឹមកូន ដូចជាមិនល្អ" ហើយក៏អាចបាត់បង់ជំនឿចិត្តទៅលើការចិញ្ចឹមកូន។

ទាំងនេះ ប្រហែលជាបញ្ហាមួយរយៈពេលក៏មិនដឹងដែរ។ ឬក៏កូននោះមានបញ្ហាលូតលាស់ជាពិសេស មានវិបត្តិក្នុងការលូតលាស់ក៏មិនដឹងដែរ។

# សូមទៅទទួលការពិនិត្យសុខភាពនៅសាលាស្រុក ឃុំ ភូមិ




នៅសាលាស្រុក ឃុំ ភូមិ គេមានធ្វើការពិនិត្យសុខភាពទារកដោយមិនយកកម្រៃ។

ការពិនិត្យសុខភាពនេះ គឺជាឱកាសមួយដ៏សំខាន់ ដើម្បីធ្វើការបញ្ជាក់អំពីស្ថានភាពសុខភាព និងការលូតលាស់របស់កូនលោកអ្នក។ សូមទៅទទួលការពិនិត្យជាមិនខាន ។

កម្លូងពេលពិនិត្យសុខភាពនេះ ខុសៗគ្នាទៅតាមរដ្ឋបាលមូលដ្ឋាននីមួយៗ។ អាស្រ័យហេតុនេះ សូមទាក់ទងនឹងរដ្ឋបាលមូលដ្ឋាន។

## ការពិនិត្យសុខភាពទារកកំពុងបំបៅ

ពេលណា ? ពេលដែលកូនមានអាយុ 3 ទៅ 4ខែ

ធ្វើអ្វី ?
･គ្រូពេទ្យធ្វើការពិនិត្យ។
･វាស់កំពស់ និងទម្ងន់។
･អាចពិគ្រោះអំពីការបារម្ភរបស់ខ្លួន នឹងការីសុខាភិបាលបាន។
･ការីអាហារូបត្ថម្ភនឹងបង្រៀនអំពីរបៀបបញ្ឈប់ការបំបៅកូន។



## ការពិនិត្យសុខភាពកូនអាយុ 1ឆ្នាំកន្លះ

ពេលណា ? កូនដែលមានអាយុពី1ឆ្នាំកន្លះ ដល់មុនអាយុ 2ឆ្នាំ

ធ្វើអ្វី ?
･គ្រូពេទ្យធ្វើការពិនិត្យ។
･គ្រូពេទ្យធ្មេញធ្វើការពិនិត្យ។
･វាស់កំពស់ និងទម្ងន់។
･អាចពិគ្រោះអំពីការបារម្ភរបស់ខ្លួននឹងការីសុខាភិបាល។



## ការពិនិត្យសុខភាពកូនអាយុ 3ឆ្នាំ

ពេលណា ?　កូនដែលមានអាយុពី 3ឆ្នាំ ដល់មុនអាយុ 4ឆ្នាំ

ធ្វើអ្វី ?
- គ្រូពេទ្យធ្វើការពិនិត្យ។
- គ្រូពេទ្យធ្មេញធ្វើការពិនិត្យ។
- វាស់កំពស់ និងទម្ងន់។
- ពិនិត្យទឹកនោម។
- ពិនិត្យភ្នែក និងត្រចៀក។
- អាចពិគ្រោះអំពីការបារម្ភរបស់ខ្លួននឹងការីសុខាភិបាល ការីអាហារូបត្ថម្ភ ការីចិត្តសាស្ត្រ។



【ការពិនិត្យភ្នែក】

ភ្នែកមានការលូតលាស់រហូតដល់អាយុខ្ទង់ 6ឆ្នាំ។ ដូច្នេះ បើសិនជារកឃើញបញ្ហាភ្នែកមិនប្រក្រតី ឬភ្នែកស្រឡេវ អាចព្យាបាលឱ្យជាបាន។

【ការពិនិត្យត្រចៀក (សោតវិញ្ញាណ)】

គឺជាការពិនិត្យដើម្បីរកមើលបញ្ហាមិនប្រក្រតីនៃការស្ដាប់ ឬជំងឺត្រចៀក។ បើសិនជាត្រចៀកមិនឮទេ អាចធ្វើឱ្យការលូតលាស់ខាងភាសាយឺតយ៉ាវ។ ដូច្នេះ សំខាន់គឺ ត្រូវរកឃើញឱ្យទាន់ពេលវេលា។

- ការពិនិត្យសុខភាពនីមួយៗ ត្រូវបានកំណត់ទៅតាមអាយុ។
- គេមិនយកថ្លៃសេវានៃការពិនិត្យសុខភាពទាំងនេះទេ។
- បើសិនជាមិនអាចទៅទទួលការពិនិត្យតាមពេលវេលាដែលត្រូវបានកំណត់ទេ សូមអញ្ជើញទៅពិគ្រោះនឹងសាលាស្រុក ឃុំ ភូមិ។



## ការពិនិត្យសុខភាពមុនចូលសាលា

ពេលណា ? នៅខ្ទង់ខែ 9 នៃមួយឆ្នាំមុនពេលកូនចូលសាលាបឋមសិក្សា គណៈកម្មការអប់រំនៃស្រុក ឃុំ ភូមិ នឹងផ្ញើសេចក្ដីជូនដំណឹង (ចំពោះកូនដែលមានសញ្ជាតិបរទេស ឬកូនគ្មានសញ្ជាតិ ហើយដែលចង់ចូលសាលាបឋមសិក្សាជប៉ុន ចាំបាច់ត្រូវដាក់ពាក្យសុំចូលសាលានៅគណៈកម្មការអប់រំនៅស្រុក ឃុំ ភូមិដែលរស់នៅ)។

ធ្វើអ្វី ? សូមទៅទទួលការពិនិត្យសុខភាពមុនចូលសាលា នៅសាលាបឋមសិក្សាដែលកូនរបស់លោកអ្នកគ្រោងនឹងចូលរៀន។
・គ្រូពេទ្យធ្វើការពិនិត្យ។
・គ្រូពេទ្យធ្មេញធ្វើការពិនិត្យ។
・វាស់កំពស់ និងទម្ងន់។
・ពិនិត្យភ្នែក និងត្រចៀក។
・ពិនិត្យមើលប្រាជ្ញាសង្ខេបៗ។



## ការពិគ្រោះអំពីការចូលសាលា

គណៈកម្មការអប់រំ និង មជ្ឈមណ្ឌលអប់រំ ទទួលការពិគ្រោះអំពីកូនពិការ ឬកូនដែលមានការបារម្ភអំពីជីវភាពរស់នៅតាមសាលាបឋមសិក្សា។ គ្រូទារកដ្ឋាន ឬសាលាមត្តេយ្យក៏អាចមានការស្នើឱ្យឪពុកម្ដាយឬអ្នកអាណាព្យាបាលទៅពិគ្រោះនឹងគណៈកម្មការអប់រំក៏មានដែរ។

ការពិគ្រោះអំពីការចូលសាលា ត្រូវកក់ពេលវេលាទុកជាមុន។ ស្ដីពីការកក់ពេលវេលា សូមសួរទៅគណៈកម្មការអប់រំ។

○ការអប់រំសម្រាប់កូនពិការ

គណៈកម្មការអប់រំធ្វើការសម្រេចនូវកន្លែងដែលកុមារត្រូវទៅសិក្សា ដោយគោរពទៅតាមឆន្ទៈរបស់ឪពុកម្ដាយ ឬកូនជាអតិបរមា។

នៅសាលាបឋមសិក្សា មាន "ថ្នាក់ជំនួយពិសេស" ឬ "ថ្នាក់ណែនាំកុមារពិការកម្រិតស្រាល"។ "សាលាជំនួយពិសេស" គឺជាសាលាសម្រាប់កុមារដែលពិការធ្ងន់។
លោកអ្នកអាចទៅធ្វើទស្សនកិច្ចនៅ "ថ្នាក់ជំនួយពិសេស" ឬ "សាលាជំនួយពិសេស" បាន។ សូមសួរទៅគណៈកម្មការអប់រំ។

# 【ឯកសារយោង】 កន្លែងអប់រំកុមារដែលចាំបាច់មានជំនួយពិសេស (ការអប់រំដោយមានជំនួយពិសេស)

## សាលាបឋមសិក្សា-អនុវិទ្យាល័យ

### ថ្នាក់សិក្សាធម្មតា

គេបានគិតដល់កុមារដែលត្រូវការជំនួយពិសេស ក្នុងការរស់នៅជាក្រុម។

**ការណែនាំតាមរយៈថ្នាក់កុមារពិការកម្រិតស្រាល (ថ្នាក់ណែនាំកុមារពិការកម្រិតស្រាល)**

គឺជាថ្នាក់ដែលការសិក្សាសឹងតែគ្រប់មុខវិជ្ជា ដូចថ្នាក់ធម្មតាដែរ តែមានកំណត់ពេលដើម្បីឱ្យទៅថ្នាក់ដោយឡែកពិសេស (ពីរ បីដង ក្នុងមួយខែ ឬមួយអាទិត្យ)។

កូនអាចទទួលនូវជំនួយពិសេសស្តីពីការសិក្សា ឬការរស់នៅ ទៅតាមកុមារម្នាក់ៗ។

### ថ្នាក់ជំនួយពិសេស

គឺជាថ្នាក់ដែលមានសិស្សតិច។ មានថ្នាក់ទាំងអស់ 7 ប្រភេទ ដោយបែងចែកទៅតាមប្រភេទនៃពិការភាព ដែលមានដូចជា ពិការភាពបញ្ញា, ពិការភាពអវយវៈ, ឈឺទន់ខ្សោយ ឬខ្សោយផ្លូវកាយ, ភ្នែកខ្សោយ, ថ្លង់, មានបញ្ហាខាងភាសា ឬគ, អូទិស្សឹម ឬមានបញ្ហាខាងអារម្មណ៍។ ប្រភេទ ឬចំនួនថ្នាក់ជំនួយពិសេស ខុសៗគ្នាតាមសាលានីមួយៗ។

＊មានសាលាខ្លះ ដែលគ្មាន "ថ្នាក់កុមារពិការកម្រិតស្រាល" ឬ "ថ្នាក់ជំនួយពិសេស" ដែរ។

## សាលាជំនួយពិសេស

គឺជាសាលាសម្រាប់កុមារដែលពិការភាពភ្នែក គ ពិការភាពអវយវៈ ឈឺទន់ខ្សោយ ពិការភាពបញ្ញា។
ចំពោះកុមារដែលមានជម្ងឺ Autism Spectrum Disorder ហើយដែលមានពិការភាពបញ្ញា គេឱ្យទៅសាលាជំនួយពិសេសសម្រាប់អ្នកពិការបញ្ញា។
គឺជាថ្នាក់ដែលមានសិស្សចំនួនតិច ហើយគេធ្វើការអប់រំជាលក្ខណៈជំនាញទៅតាមពិការភាព។





# សូមទៅពិគ្រោះ

លក្ខណៈពិសេស និង ការលូតលាស់របស់កុមារម្នាក់ៗគឺផ្សេងៗគ្នា។ បើសិនជាមានការបារម្ភអ្វីមួយ សូមទៅពិគ្រោះឱ្យបានទាន់ពេលវេលា ដើម្បីចាត់វិធានការទៅតាមលក្ខណៈពិសេសរបស់កុមារម្នាក់ៗ គឺជាការសំខាន់។

○បើសិនជាមានការបារម្ភអំពីការចិញ្ចឹមកូន ឬអំពីការលូតលាស់របស់កូន ជាបឋម សូមទៅពិគ្រោះនឹងការីសុខាភិបាលនៃស្រុក ឃុំ ភូមិ។

○បើសិនជាកូនទៅទារកដ្ឋាន ឬសាលាមត្តេយ្យ សូមពិគ្រោះនឹងគ្រូនៅសាលានោះជាប្រចាំ។

○នៅតាមស្រុក ឃុំ ភូមិខ្លះ គេទទួលការពិគ្រោះពិសេសដោយអ្នកពីគ្រោះអំពីការលូតលាស់របស់កុមារ ឬការពិគ្រោះចល័តក៏មានដែរ។

○នៅស្រុក ឃុំ ភូមិខ្លះ គេមានថ្នាក់ជំនួយសម្រាប់ឱ្យកូននិងឪពុកម្ដាយទៅជាមួយគ្នាក៏មានដែរ។ ដូច្នេះ លោកអ្នកអាចពាក់ព័ន្ធផ្ទាល់នឹងការអប់រំស្របទៅតាមការលូតលាស់របស់កូនបាន។

## អាចពិគ្រោះតាមកន្លែងខាងក្រោមនេះដែរ

○មន្ទីរសុខភាព, មជ្ឈមណ្ឌលសុខភាព
○មជ្ឈមណ្ឌលជំនួយសម្រាប់ការលូតលាស់របស់កុមារ
○មជ្ឈមណ្ឌលជំនួយក្នុងការចិញ្ចឹមកូន, កន្លែងជួបជុំគ្នា ជាដើម





※អ្នកទទួលការពិគ្រោះ កន្លែងទទួលការពិគ្រោះ គឺខុសៗគ្នាទៅតាមរដ្ឋបាលមូលដ្ឋាននីមួយៗ ។
ព័ត៌មានលំអិត សូមសួរការីសុខាភិបាល។

# ស្ថាប័នពិគ្រោះនៅស្រុក ឃុំ ភូមិ នៃលំនៅដ្ឋានលោកអ្នក

នៅស្រុក ឃុំ ភូមិ មានកន្លែងពិគ្រោះជាច្រើន។
បើសិនជាមានការបារម្ភអំពីកូន សូមអញ្ជើញទៅពិគ្រោះ។

| ឈ្មោះអង្គភាព | អ្នកដែលជាមុខសញ្ញា | ថ្ងៃ-ម៉ោង | លេខទូរស័ព្ទ | ការបកប្រែ |
|---|---|---|---|---|
| | ខ្លឹមសារនៃការពិគ្រោះដែលអាចទទួល | | | |
| [ឧទាហរណ៍អំពីរបៀបបំពេញ]<br>○មជ្ឈមណ្ឌលលូតលាស់នៃស្រុក ...... | កូនដែលមានអាយុក្រោម18ឆ្នាំ<br>ឪពុកម្តាយឬអ្នកអាណាព្យាបាល | ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ<br>9:00～17:00<br>ថ្ងៃបុណ្យ ឈប់សម្រាក | (04)<br>○○○-○○○ | △អាចមួយភាគ(ភាសា○○) |
| | ឧ. ) ការពិគ្រោះអំពីការលូតលាស់របស់កូន, ការពិគ្រោះអំពីការពិនិត្យសុខភាព ការមានផ្ទៃពោះ ការសម្រាលកូន ការចិញ្ចឹមកូន | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# អ្វីទៅ វិបត្តិក្នុងការលូតលាស់ ?

"វិបត្តិក្នុងការលូតលាស់" គឺជាពិការភាពដែលពាក់ព័ន្ធនឹងការលូតលាស់នៃមុខងាររបស់ខួរក្បាល ហើយភាគច្រើន គឺជាពិការភាពពីកំណើត។

វិបត្តិក្នុងការលូតលាស់ មានច្រើនប្រភេទ ដូចរូបខាងក្រោមនេះ។ ទោះជាប្រភេទពិការភាពដូចគ្នាក៏ដោយ ក៏អាការៈវាខុសៗគ្នាទៅតាមម្នាក់ៗ។ លើសពីនេះ មានអ្នកខ្លះមានវិបត្តិក្នុងការលូតលាស់ច្រើនប្រភេទក៏មានដែរ។

អាចមានករណីបញ្ហាលូតលាស់យឺតយ៉ាវក៏មានដែរ

**វិបត្តិក្នុងការលូតលាស់ដែលកើតមានច្រើន**

(Autism Spectrum Disorder: ASD)

អូទិស្សឹម | Asperger's Syndrome

- ការយឺតយ៉ាវនៃកាយលូតលាស់ខាងភាសា (ចំពោះជម្ងឺ Asperger's syndrome មិនមានការយឺតយ៉ាវខាងភាសាទេ)
- ពិបាកប្រាស្រ័យទាក់ទង
- មានបញ្ហាក្នុងការទំនាក់ទំនងនឹងមនុស្ស ឬសង្គម
- សកម្មភាពមានលំនាំដដែលៗ ចំណង់ចិត្តមានការលំអៀង ឬគិតជ្រុល
- អារម្មណ៍រសើបខ្លាំង ឬមិនមានអារម្មណ៍ មិនប៉ិនប្រសប់

**Attention Deficit Hyperactivity Disorder AD/HD**

(ជម្ងឺកង្វះការយកចិត្តទុកដាក់-មិនអាចផ្តោតអារម្មណ៍ ពិការភាពកង្វះការយកចិត្តទុកដាក់-មិនអាចផ្តោតអារម្មណ៍)

- មិនអាចផ្តោតអារម្មណ៍ពបាន
- មិនអាចនៅស្ងៀមបាន
- ធ្វើសកម្មភាពមិនព្រៀងទុក

**វិបត្តិក្នុងការសិក្សា LD**

(Localized learning disorder, Localized learning disability)

- មិនមែនបញ្ហាលូតលាស់យឺតទាំងស្រុងទេ។ ក៏ប៉ុន្តែ "ការអាន" ឬ "ការសរសេរ" ឬ "ការគិតលេខ" អាចលូតលាស់យឺត។

※ក្រៅពីនេះ មាន Gilles De La Tourette Syndrome, ជម្ងឺនិយាយមិនច្បាស់, ពិការភាពក្នុងការធ្វើចលនាសហការគ្នាដោយសារការលូតលាស់ ជាដើម ក៏ត្រូវបានចំណាត់ថាជា វិបត្តិក្នុងការលូតលាស់ដែរ។

និយមន័យនៃវិបត្តិក្នុងការលូតលាស់ ក្នុងច្បាប់ជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ (មាត្រា 2)...

"វិបត្តិក្នុងការលូតលាស់" គឺជាអ្នកដែលមានពិការភាពក្នុងការលូតលាស់ (ពិការភាពនៃមុខងាររបស់ខួរក្បាល ដែលមានដូចជា អូទិស្សឹម, Asperge's syndrome, វិបត្តិក្នុងការលូតលាស់ដែលរាលដាលខ្លាំង, វិបត្តិក្នុងការសិក្សា ឬ LD, AD/HD ជាដើម ហើយភាគច្រើន កើតជម្ងឺនេះពីក្មេង) ហើយទទួលនូវការកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារវិបត្តិក្នុងការលូតលាស់ ឬឧបស័គសង្គម" ※ឧបស័គដែលមានក្នុង F80-98 នៃ ICD-10

# ច្បាប់ស្តីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់




នៅជប៉ុន មាន "ច្បាប់ស្តីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់"។ នេះគឺជាច្បាប់សម្រាប់ទ្រទ្រង់អ្នកមានវិបត្តិក្នុងការលូតលាស់ (ពីកូនក្មេង ដល់មនុស្សធំ) និងក្រុមគ្រួសារអ្នកនោះ។

ច្បាប់ស្តីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ មានគោលបំណងបង្កើតសង្គមមួយដែលអាចធ្វើឱ្យកូនដែលមានវិបត្តិក្នុងការលូតលាស់ អាចលូតលាស់ប្រកបដោយសុខភាពល្អ និងអាចឱ្យគ្រួសារកុមារនោះ គ្មានការបារម្ភក្នុងការចិញ្ចឹមកូន។

## ស្តីពីមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់

ដើម្បីឱ្យអ្នកមានវិបត្តិក្នុងការលូតលាស់ ឬក្រុមគ្រួសារអ្នកនោះ អាចមានជីវភាពរស់នៅដោយគ្មានការបារម្ភនៅក្នុងសហគមន៍ មានស្ថាប័នជាច្រើន ដែលអាចពិគ្រោះបាន។

"មជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់" មានតួនាទីដ៏សំខាន់ក្នុងការជួយនៅតាមរាជធានីនិងខេត្តនីមួយៗ។ មជ្ឈមណ្ឌលត្រូវបានបង្កើតឡើង នៅគ្រប់រាជធានីនិងខេត្ត ព្រមទាំងក្រុងដែលកំណត់ដោយក្រឹត្យ។

○ព័ត៌មានស្តីពីមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ទូទាំងប្រទេស មាននៅក្នុងគេហទំព័រខាងក្រោមនេះ។

មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់

http://www.rehab.go.jp/ddis/



【មជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់នៃតំបន់លំនៅដ្ឋានរបស់លោកអ្នក】

ឈ្មោះមជ្ឈមណ្ឌល :

លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង :



# ស្ដីពីមន្ទីរពេទ្យ



ការពិនិត្យអំពីវិបត្តិក្នុងការលូតលាស់ ត្រូវធ្វើដោយគ្រូពេទ្យជំនាញ (គ្រូពេទ្យកុមារ, គ្រូពេទ្យជម្ងឺផ្លូវចិត្តកុមារ)។

បើសិនជាចង់ឱ្យគេពិនិត្យ សូមត្រៀមដូចតទៅ។

○សូមស្វែងរកមន្ទីរពេទ្យដែលមានគ្រូពេទ្យជំនាញ។ សូមទៅពិគ្រោះនឹងការីសុខាភិបាល ឬមជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់តាមស្រុក ឃុំ ភូមិ (មន្ទីរពេទ្យភាគច្រើន ចាំបាច់កក់ជាមុន)។

○ពេលទៅទទួលការពិនិត្យលើកដំបូង សូមយកប័ណ្ណធានារ៉ាប់រងសុខភាព និង សៀវភៅសុខភាពម្ដាយនិងកូនតាមខ្លួនផង។

○សូមសរសេរទុកជាមុនអំពីអ្វីៗដែលជាការបារម្ភអំពីកូន និងស្ថានភាពនៅផ្ទះ ឬនៅទារកដ្ឋាន ជាដើម។



## ការពិនិត្យ, វិធីព្យាបាលពិសេស

ប្រសិនបើមានភាពចាំពាច់ នៅមន្ទីរពេទ្យ បុគ្គលិកជំនាញនឹងធ្វើការពិនិត្យ ឬព្យាបាលពិសេស។

ការពិនិត្យ មានដូចជា ការពិនិត្យអំពីបញ្ញា និងការលូតលាស់, ការពិនិត្យត្រចៀក, ការពិនិត្យរលកខួរក្បាល ជាដើម។

ការព្យាបាលពិសេស មានដូចជា វិធីព្យាបាលដោយចលនា វិធីព្យាបាលរាងកាយ វិធីព្យាបាលឧបស័គខាងភាសា ឬសោតវិញ្ញាណ វិធីព្យាបាលផ្លូវចិត្ត។

ខ្លឹមសារនៃការព្យាបាល គឺខុសៗគ្នាទៅតាមស្ថានភាពរបស់កុមារម្នាក់ៗ។

## បើសិនជាគ្រូពេទ្យថា កូនមានវិបត្តិក្នុងការលូតលាស់ ......

ពេលគ្រូពេទ្យថា កូនមានវិបត្តិក្នុងការលូតលាស់ លោកអ្នកច្បាស់ជាមានការបារម្ភខ្លាំងណាស់។ ក៏ប៉ុន្តែ តាមរយៈការរៀបចំបរិស្ថាន និងចាត់ចែងសមស្រប ស្ថានភាពរបស់កូនច្បាស់ជានឹងមានស្ថានភាពល្អបន្តិចម្ដងៗ។

ស្ដីពីរបៀបចាត់ចែង សូមពិគ្រោះនឹងគ្រូពេទ្យទទួលបន្ទុក ឬបុគ្គលិកជំនាញ។



# ការប្រើថ្នាំ ដើម្បីឱ្យមានជីវភាពស្រួលបួល

ក្នុងករណីដែលគ្រូពេទ្យពិនិត្យមើល ហើយឃើញថា ចាំបាច់ប្រើថ្នាំ គេនឹងណែនាំឱ្យញ៉ាំថ្នាំ។ ស្តីពីអានុភាព និងប្រតិកម្មបន្ទាប់បន្សំរបស់ថ្នាំ សូមពិភាក្សាជាមួយគ្រូពេទ្យ ទទួលបន្ទុកឱ្យបានគ្រប់គ្រាន់។

សូមបញ្ជាក់ថា មិនអាចព្យាបាលវិបត្តិក្នុងការលូតលាស់តាមរយៈថ្នាំបានទេ។ ក៏ប៉ុន្តែ អាការៈរោគមួយចំនួនរបស់កុមារមានវិបត្តិក្នុងការលូតលាស់ អាចធូរស្រាល ដោយសារថ្នាំបាន។

【ថ្នាំដែលប្រើច្រើន】




| | |
|---|---|
| ○ថ្នាំរំញោចសសៃប្រសាទ | សម្រាលអាការៈ AD/HD, ការមិនប្រយ័ត្ន និងសកម្មភាពមិនព្រៀងទុក អាចធូរស្រាល។ |
| ○ថ្នាំបង្ការការបារម្ភ | សម្រាលការបារម្ភ។ |
| ○ថ្នាំចិត្តរោគ | សម្រាលអាការៈរំជើបរំជួល ឬរើរវាយ។ |
| ○ថ្នាំព្យាបាលជម្ងឺឆ្កួតជ្រូក | សម្រាលការប្រកាច់ដោយសារជម្ងឺឆ្កួតជ្រូក។ |
| ○ថ្នាំឱ្យគេងបាន | ធ្វើឱ្យអាចគេងបានស្រួលតាមចង្វាក់នៃជីវភាពរស់នៅ។ |

តាមរយៈការប្រើថ្នាំ អាការៈរោគនឹងធូរស្រាល ហើយការរស់នៅរបស់កូននោះក៏ល្អទៅតាមនោះដែរ។

សូមឱ្យកូនញ៉ាំទៅតាមចំនួនដង និងបរិមាណដែលគ្រូពេទ្យប្រាប់។

☆បើសិនជាស្តីពីសេចក្តីពន្យល់របស់គ្រូពេទ្យ ឬបុគ្គលិកជំនាញនៅមន្ទីរពេទ្យ មានអ្វីមិនយល់ សូមសួរគេឱ្យបានច្បាស់លាស់ កុំឱ្យខ្លាចចិត្ត។

☆ក្រៅពីនេះ ក៏អាចពឹងពាក់គិលានុបដ្ឋាក... 



# ស្តីពីសៀវភៅជនពិការ

បើសិនជាមានសៀវភៅបញ្ជាក់ថា មានពិការភាព (សៀវភៅជនពិការ) យើងអាចទទួលសេវាកម្មសុខុមាលភាពផ្សេងៗ ទៅតាមប្រភេទ និងកម្រិតនៃពិការភាព (ប្រាក់ឧបត្ថម្ភ ជាដើម)។ អ្នកដែលចង់បានសៀវភៅនេះ សូមទៅបំពេញបែបបទនៅសាលាស្រុក ឃុំ ភូមិ។

សៀវភៅនេះ មាន 3ប្រភេទ គឺ 〝សៀវភៅព្យាបាលថែទាំ〟 〝សៀវភៅសុខភាព និងសុខុមាលភាពសម្រាប់ជនពិការផ្លូវចិត្ត〟 និង〝សៀវភៅជនពិការរូបកាយ〟។

＊ពេលមានសៀវភៅនេះ នឹងមានការងាយស្រួលក្នុងការបំពេញបែបបទទទួលសេវាកម្មសុខុមាលភាព។

＊<u>ទឹកប្រាក់ឧបត្ថម្ភ គឺខុសៗគ្នាទៅតាមប្រភេទ និងកម្រិតនៃពិការភាព។</u>

＊<u>អ្នកដែលជាមុខសញ្ញានៃការទទួល និងខ្លឹមសារនៃសេវាកម្ម ជាដើម អាចខុសគ្នាមួយភាគ ទៅតាមស្រុក ឃុំ ភូមិ។</u>

ស្តីពីខ្លឹមសារលំអិត សូមសួរតាមសាលាស្រុក ឃុំ ភូមិនៃលំនៅដ្ឋានរបស់លោកអ្នក។



【 ឧទាហរណ៍ 】

○អាចទទួលបាននូវប្រាក់ឧបត្ថម្ភ។

○ថ្លៃពេទ្យដែលបានបង់ឱ្យមន្ទីរពេទ្យ នឹងត្រឡប់មកវិញមួយភាគ។

○ថ្លៃពន្ធនឹងចុះថោក។

○ថ្លៃជិះរថភ្លើង រថយន្តក្រុង យន្តហោះ (ក្នុងស្រុក) នឹងចុះថោក។

○ថ្លៃប្រើផ្លូវយកកម្រៃ នឹងចុះថោក។

･ក្រៅពីនេះ ក៏មានសេវាកម្មផ្សេងៗទៀតដែរ។



## សៀវភៅព្យាបាលថែទាំ



អ្នកដែលជាមុខសញ្ញា

○អ្នកពិការបញ្ញា

○អ្នកដែលមានវិបត្តិក្នុងការលូតលាស់ និងពិការភាពបញ្ញា

វិធីសុំ

○នៅកន្លែងពិគ្រោះអំពីកុមារ (មជ្ឈមណ្ឌលពិគ្រោះអំពីកុមារ) គេនឹងធ្វើការវិនិច្ឆ័យអំពីកម្រិតនៃពិការភាព។

(អ្នកដែលមានអាយុពី18ឆ្នាំឡើងទៅ ត្រូវទៅទទួលការវិនិច្ឆ័យនៅកន្លែងពិគ្រោះអំពីការស្តារនីតិសម្បទាជនពិការបញ្ញា)។

ចំណុចដែលត្រូវប្រយ័ត្ន

កម្រិតនៃពិការភាពបញ្ញាអាចប្រែប្រួលទៅតាមការលូតលាស់។ ហេតុនេះហើយ ត្រូវធ្វើការវិនិច្ឆ័យសារជាថ្មីតាមពេលវេលាដែលត្រូវបានកំណត់។ ពេលវេលានោះខុសៗគ្នាទៅតាមរាជធានី ខេត្តនៃលំនៅដ្ឋានរបស់លោកអ្នក ជាដើម។

## សៀវភៅសុខភាព និងសុខុមាលភាពសម្រាប់ជនពិការផ្លូវចិត្ត

អ្នកដែលជាមុខសញ្ញា

○អ្នកដែលពិការផ្លូវចិត្តដូចខាងក្រោមនេះ ហើយដែលមានស្ថានភាពចាំបាច់ត្រូវការជំនួយក្នុងជីវភាពរស់នៅជាបន្តបន្ទាប់

- ･វិបត្តិក្នុងការលូតលាស់
- ･ជម្ងឺខាងអារម្មណ៍ ដូចជាធ្លាក់ទឹកចិត្ត ឬម្តងសប្បាយម្តងធ្លាក់ទឹកចិត្ត
- ･Schizophrenia(ជម្ងឺផ្លូវចិត្តដែលវង្វេងវង្វាយឃើញផ្តេសផ្តាស)
- ･ជម្ងឺឆ្កួតជ្រូក
- ･ញៀនថ្នាំ
- ･ពិការមុខងារខួរក្បាលកម្រិតខ្ពស់
- ･ជម្ងឺផ្លូវចិត្ត ក្រៅពីនេះ (ពាក់ព័ន្ធនឹងស្ត្រេស ជាដើម)



វិធីសុំ

○ទៅបំពេញបែបបទតាមសាលាស្រុក ឃុំ ភូមិ។

○ឯកសារចាំបាច់មានដូចតទៅ ៖

① ពាក្យសុំដែលមាននៅកន្លែងសុំ

② សំបុត្រពេទ្យ (អ្នកដែលបានទទួលប្រាក់និវត្តន៍សម្រាប់ជនពិការ អាចដាក់ឯកសារកូពីក៏បាន)

③ រូបថតសាមីខ្លួន

ចំណុចដែលត្រូវប្រយ័ត្ន

ចាំបាច់ត្រូវធ្វើបែបបទ 2 ឆ្នាំម្តង ដើម្បីពន្យារ។ ពេលនោះ ក៏ត្រូវមានសំបុត្រពេទ្យដែរ។

# ព័ត៌មានយោង

មន្ទីរពេទ្យ ឬស្ថាប័នពិគ្រោះខ្លះ មានបុគ្គលិកចេះភាសាបរទេសដែរ ហើយមានកន្លែងខ្លះ គេមាន Apps បកប្រែ។

នៅតំបន់មួយចំនួន រដ្ឋបាលមូលដ្ឋានមានសេវាកម្មបញ្ជូនអ្នកបកប្រែដែរ។

## សេវាកម្មពិគ្រោះជាភាសាបរទេស



មានសេវាកម្មពិគ្រោះតាមរយៈទូរស័ព្ទដែលជនបរទេសអាចប្រើបាន។ នេះមិនមែនជាកន្លែងពិគ្រោះអំពីវិបត្តិក្នុងការលូតលាស់ទេ។ ប៉ុន្តែ លោកអ្នកអាចពិគ្រោះស្តីពីមន្ទីរពេទ្យដែលអាចប្រើភាសាកំណើត ឬស្តីពីការរកអ្នកបកប្រែបាន។

◆ **គេហទំព័រជំនួយជីវភាពរស់នៅសម្រាប់ជនបរទេស**

មានព័ត៌មានចាំបាច់សម្រាប់ការរស់នៅៗជប៉ុនរបស់លោកអ្នក។ ក្រៅពីនេះ ក៏អាចស្វែងរកកន្លែងពិគ្រោះក្នុងតំបន់ដែរ។

http://www.moj.go.jp/isa/support/portal/index.html

◆ សេវាកម្មព័ត៌មានតាមរយៈការពិគ្រោះតាមទូរស័ព្ទ មជ្ឈមណ្ឌលព័ត៌មានវិស័យពេទ្យអន្តរជាតិ AMDA

មានការណែនាំឱ្យស្គាល់ស្ថាប័នព្យាបាលដែលអាចប្រើភាសាកំណើតរបស់លោកអ្នក ហើយក៏មានសេវាកម្មណែនាំអំពីរបបសុខុមាលភាពវេជ្ជសាស្ត្រ (※គេនិយាយភាសាជប៉ុនងាយស្រួលយល់)។

លេខាធិការដ្ឋានការិយាល័យតូក្យូ (ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ 10:00～15:00)

ទូរស័ព្ទ:03-6233-9266

https://www.amdamedicalcenter.com/



# Apps បកប្រែ

## ◆ បកប្រែដោយ Google Translate [អភិវឌ្ឍដោយ:google,Inc]

មាន Apps សម្រាប់បកប្រែឯកសារ, បកប្រែដោយប្រើកាមេរ៉ា, បកប្រែតាមការសរសេរដៃ, បកប្រែតាមសម្លេង។

សុទ្ធតែដោនឡូដបាន ហើយប្រើដោយឥតគិតថ្លៃ។

សូមដោនឡូដពី Google Play ឬ App Store។

## ◆ Apps បកប្រែតាមសម្លេងពហុភាសា VoiceTra

[អភិវឌ្ឍដោយ:NICT(នីតិបុគ្គលស្រាវជ្រាវ និងអភិវឌ្ឍជាតិ ទីភ្នាក់ងារស្រាវជ្រាវព័ត៌មាន និងទូរគមនាគមន៍)]

គឺជា Apps ដែលបកប្រែជាសម្លេង នៅពេលដែលលោកអ្នកនិយាយភាសាបរទេសទៅកាន់ម៉ាស៊ីនដែលមាន Apss នោះ។

Apps នេះអាចបកប្រែ 31 ភាសា ហើយអាចដោនឡូដ ហើយប្រើដោយឥតគិតថ្លៃ។

[http://voicetra.nict.go.jp/](http://voicetra.nict.go.jp/)






# ព័ត៌មានស្តីពីការអប់រំតាមសាលា

◆ គេហទំព័រព័ត៌មានស្តីពីការអប់រំទូទៅតាមសាលា【ក្រសួងអប់រំ និងវិទ្យាសាស្ត្រ】

○ សូមស្វាគមន៍លោកអ្នកដែលបានចូលដល់ CLARINET

គឺជាគេហទំព័រពាក់ព័ន្ធនឹងការអប់រំក្មេងរស់នៅបរទេស កុមារត្រឡប់មកជប៉ុនវិញ និងកុមារបរទេស ជាដើម។

http://www.mext.go.jp/a_menu/shotou/clarinet/003.htm

○ CASTA-NET

គឺជាគេហទំព័រស្វែងរកព័ត៌មានស្តីពីជំនួយក្នុងការសិក្សាសម្រាប់កុមារ ឬសិស្សដែលមានពាក់ព័ន្ធនឹងបរទេស។

https://casta-net.mext.go.jp/

○ គម្រោងពហុភាសា-សាលា

គឺជាគេហទំព័រជំនួយក្នុងការសរសេរឯកសារពហុភាសា ដើម្បីតភ្ជាប់សាលា និងគ្រួសារដែលមានកុមារ ឬសិស្សដែលមានពាក់ព័ន្ធនឹងបរទេស។

http://www.tagengo-gakko.jp/index.html

# ព័ត៌មានស្តីពីវិបត្តិក្នុងការលូតលាស់

○ មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់

តាមរយៈគេហទំព័រនេះ លោកអ្នកអាចរកមើលព័ត៌មានថ្មីៗដែលអាចជឿទុកចិត្តបាន ស្តីពីព័ត៌មានមូលដ្ឋាននៃវិបត្តិក្នុងការលូតលាស់ លក្ខណៈពិសេសនៃវិបត្តិក្នុងការលូតលាស់ និងការឆ្លើយតបចំពោះបញ្ហានេះ ព្រមទាំងប្រព័ន្ធទ្រទ្រង់អ្នកមានវិបត្តិក្នុងការលូតលាស់ សកម្មភាពរបស់ជប៉ុនពាក់ព័ន្ធនឹងបញ្ហានេះ និងនិន្នាការក្នុងពិភពលោក ជាដើម។

http://www.rehab.go.jp/ddis/

○ មជ្ឈមណ្ឌលជម្រុញការអប់រំអ្នកមានវិបត្តិក្នុងការលូតលាស់

អាចរកមើលវិធីទ្រទ្រង់ និងណែនាំកូនដែលមានវិបត្តិក្នុងការលូតលាស់ ឯកសារស្រាវជ្រាវ សម្ភារៈសិក្សា ឬឧបករណ៍សម្ភារៈជំនួយពាក់ព័ន្ធនឹងកូនដែលមានវិបត្តិក្នុងការលូតលាស់បាន។

ក្រៅពីនេះ ក៏មានមេរៀនស្តីពីការការបណ្តុះបណ្តាលតាមរយៈវីដេអូសម្រាប់គ្រូ ព្រមទាំងច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធ ជាដើម របស់រដ្ឋ។

http://icedd_new.nise.go.jp/

# កម្រងពាក្យខ្មែរជប៉ុន

| ខ្មែរ | ជប៉ុន សរសេរជាអក្សរឡាតាំង | ជប៉ុន ដោយមានភ្ជាប់នូវអក្សរហ៊ីរ៉ាហ្គាណា |
|---|---|---|
| កន្លែងពិគ្រោះអំពីការស្តារនីតិសម្បទាជនពិការបញ្ញា | Chiteki shōgaisha kōsei sōdanjo | 知的障害者更生相談所 |
| ការកក់ | Yoyaku | 予約 |
| ការធ្វើតេស្តបញ្ញា | Chinō kensa | 知能検査 |
| ការធ្វើតេស្តអំពីការលូតលាស់ | Hattatsu kensa | 発達検査 |
| ការពិគ្រោះ | Sōdan | 相談 |
| ការពិគ្រោះចល័ត | Junkai sōdan | 巡回相談 |
| ការពិគ្រោះពិសេសសម្រាប់ម្នាក់ៗ | Kobetsu sōdan | 個別相談 |
| ការពិគ្រោះអំពីការចូលសាលា | Shūgaku sōdan | 就学相談 |
| ការពិនិត្យ, ការធ្វើតេស្ត | Kensa | 検査 |
| ការពិនិត្យនិងវិនិច្ឆ័យ | Shindan | 診断 |
| ការពិនិត្យភ្នែក | Shikaku kensa | 視覚検査 |
| ការពិនិត្យសុខភាពកុមារអាយុ 3ឆ្នាំ | Sansai ji kenkō shinsa (kenshin) | 3歳児健康診査(健診) |
| ការពិនិត្យសុខភាពកុមារអាយុមួយឆ្នាំកន្លះ | Issai rokkagetsuji kenkō shinsa (kenshin) | 1歳6 か月児健康診査(健診) |
| ការពិនិត្យសុខភាពទារក | Nyūji kenshin | 乳児健診 |
| ការពិនិត្យសុខភាពទារក (ពិនិត្យសុខភាព) | Nyūyōji kenkō shinsa (kenshin) | 乳幼児健康診査(健診) |
| ការពិនិត្យសុខភាពពេលចូលសាលា | Shūgakuji kenkō shindan | 就学時健康診断 |
| ការពិនិត្យសោតវិញ្ញាណ | Chōkaku kensa | 聴覚検査 |
| ការពិនិត្យរលកខួរក្បាល | Nōha kensa | 脳波検査 |
| ការលូតលាស់ | Hattatsu | 発達 |
| ការីចិត្តសាស្រ្ត | Shinrishi | 心理士 |
| ការីសុខាភិបាល | Hokenshi | 保健師 |
| ការីអាហារូបត្ថម្ភ | Eiyōshi | 栄養士 |
| គណៈកម្មការអប់រំ | Kyōiku iinkai | 教育委員会 |
| គ្រូទារកដ្ឋាន | Hoikushi | 保育士 |
| គ្រូពេទ្យ (វេជ្ជបណ្ឌិត) | Ishi/isha | 医師／医者 |
| គ្រូពេទ្យកុមារ | Shōnikai | 小児科医 |
| គ្រូពេទ្យចិត្តសាស្រ្តកុមារ | Jidō seishinkai | 児童精神科医 |
| គ្រូពេទ្យធ្មេញ | Shikaishi/haisha | 歯科医師／歯医者 |
| ច្បាប់ស្តីពីជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ | Hattatsu shōgai sha shien hō | 発達障害者支援法 |
| ជម្ងឺកង្វះការយកចិត្តទុកដាក់-មិនអាចផ្តោតអារម្មណ៍ ហៅកាត់ថា ADHD | Chūi kekkan tadōsē shōgai/ADHD | 注意欠陥多動性障害／ADHD |
| ជម្ងឺឆ្កួតជ្រូក | Tenkan | てんかん |

| | | |
|---|---|---|
| ជម្ងឺញៀនថ្នាំ | Yakubutsu izon shō | 薬物依存症 |
| ជម្ងឺធ្លាក់ទឹកចិត្ត | Utsu | うつ |
| ជម្ងឺពាក់ព័ន្ធនឹងស្ត្រេស | Sutoresu sē shōgai | ストレス性障害 |
| ឈឺទន់ខ្សោយ, សុខភាពមិនល្អ | Byōjaku/Shintai kyojaku | 病弱／身体虚弱 |
| ត្រចៀកធ្ងន់ | Nanchō | 難聴 |
| ថ្នាក់ជំនួយពិសេស | Tokubetsu shien gakkyū | 特別支援学級 |
| ថ្នាក់ណែនាំអ្នកពិការកម្រិតស្រាល | Tsūkyū shidō kyōshitsu | 通級指導教室 |
| ថ្នាក់ធម្មតា | Tsūjō gakkyū | 通常学級 |
| ថ្នាំចិត្តរោគ | Kō seishinbyō yaku | 抗精神病薬 |
| ថ្នាំបង្ការការបារម្ភ | Kō fuan yaku | 抗不安薬 |
| ថ្នាំពេទ្យ | Kusuri | 薬 |
| ថ្នាំព្យាបាលជម្ងឺឆ្កួតជ្រូក | Kō tenkan yaku | 抗てんかん薬 |
| ថ្នាំរំញោចប្រព័ន្ធសរសៃខួរ | Chūsū shinkei shigeki yaku | 中枢神経刺激薬 |
| ថ្នាំឱ្យគេងបាន | Suimin yaku | 睡眠薬 |
| ទារកដ្ឋាន | Hoikuen | 保育園 |
| និយាយមិនច្បាស់ | Kitsuon | 吃音 |
| ប័ណ្ណធានារ៉ាប់រងសុខភាព | Hoken shō | 保険証 |
| បុគ្គលិកជំនាញ | Senmon sutaffu | 専門スタッフ |
| ប្រតិកម្មបន្ទាប់បន្សំ | Fuku sayō | 副作用 |
| ប្រាក់និវត្តន៍សម្រាប់ជនពិការ | Shōgai nenkin | 障害年金 |
| ប្រាក់ឧបត្ថម្ភ | Teate | 手当 |
| ភ្នែកខ្សោយ | Jakushi | 弱視 |
| ពិការភាព | Shōgai | 障害 |
| ពិការភាពបញ្ញា | Chiteki shōgai | 知的障害 |
| ពិការភាពអវយវៈ, ពិការភាពរាងកាយ | Shitai fujiyū/shintai shōgai | 肢体不自由／身体障害 |
| មជ្ឈមណ្ឌលជម្រុញការអប់រំអ្នកមានវិបត្តិក្នុងការលូតលាស់ | Hattatsu shōgai kyōiku suishin sentā | 発達障害教育推進センター |
| មជ្ឈមណ្ឌលជំនួយក្នុងការចិញ្ចឹមកូន | Kosodate shien sentā | 子育て支援センター |
| មជ្ឈមណ្ឌលជំនួយសម្រាប់ការលូតលាស់របស់កុមារ | Kodomo hattatsu shien sentā | こども発達支援センター |
| មជ្ឈមណ្ឌលជំនួយចំពោះអ្នកមានវិបត្តិក្នុងការលូតលាស់ | Hattatsu shōgai sha shien sentā | 発達障害者支援センター |
| មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់ | Hattatsu shōgai jōhō shien sentā | 発達障害情報・支援センタ― |
| មជ្ឈមណ្ឌលសុខភាព | Hoken sentā | 保健センター |
| មជ្ឈមណ្ឌលអប់រំ | Kyōiku sentā | 教育センター |
| មន្ទីរពេទ្យ | Byōin | 病院 |
| វិធីព្យាបាលចិត្តសាស្ត្រ | Shinri ryōhō | 心理療法 |

| | | |
|---|---|---|
| វិធីព្យាបាលដោយចលនា | Sagyō ryōhō | 作業療法 |
| វិធីព្យាបាលរាងកាយ | Rigaku ryōhō | 理学療法 |
| វិធីព្យាបាលឧបស័គខាងភាសា ឬសោតវិញ្ញាណ | Gengo chōkaku ryōhō | 言語聴覚療法 |
| វិបត្តិក្នុងការលូតលាស់ | Hattatsu shōgai | 発達障害 |
| សាលាជំនួយពិសេស | Tokubetsu shien gakkō | 特別支援学校 |
| សាលាបឋមសិក្សា | Shōgakkō | 小学校 |
| សាលាមត្តេយ្យ | Yōchien | 幼稚園 |
| សៀវភៅជនពិការ | Shōgaisha techō | 障害者手帳 |
| សៀវភៅជនពិការរាងកាយ | Shintai shōgaisha techō | 身体障害者手帳 |
| សៀវភៅព្យាបាលនិងថែទាំ | Ryōiku techō | 療育手帳 |
| សៀវភៅសុខភាព និងសុខុមាលភាពសម្រាប់ជនពិការផ្លូវចិត្ត | Seishin shōgaisha hoken fukushi techō | 精神障害者保健福祉手帳 |
| សៀវភៅសុខភាពម្តាយនិងកូន | Boshi kenkō techō (Boshi techō) | 母子健康手帳(母子手帳) |
| សេវាកម្មសុខុមាលភាព | Fukushi sābisu | 福祉サービス |
| សំបុត្រពេទ្យ | Shindansho | 診断書 |
| អនុវិទ្យាល័យ | Chūgakkō | 中学校 |
| អានុភាព, ប្រសិទ្ធភាព | Kōka/sayō | 効果／作用 |
| អារម្មណ៍មិននឹងនរ | Jōcho shōgai | 情緒障害 |
| អារម្មណ៍មិនល្អ | Kibun shōgai | 気分障害 |
| អូទិស្សឹម / ASD | Jiheishō/ASD | 自閉症／ASD |
| អ្នកបកប្រែ | Tsūyaku | 通訳 |
| ឧបស័គក្នុងការធ្វើចលនាសហការគ្នាដោយសារការលូតលាស់ | Hattatsu sē kyōchō undō shōgai | 発達性協調運動障害 |
| ឧបស័គ្គក្នុងការរៀន | Gakushū shōgai/LD | 学習障害／LD |
| ឧបស័គខាងភាសា | Gengo shōgai | 言語障害 |
| ឧបស័គមុខងារខួរក្បាលកម្រិតខ្ពស់ | Kōjinō kinō shōgai | 高次脳機能障害 |
| Bipolar disorder | Sōkyokusē shōgai | 双極性障害 |
| Schizophrenia(ជម្ងឺផ្លូវចិត្តដែលរវើរវាយឃើញផ្ដេសផ្ដាស) | Tōgō shicchō shō | 統合失調症 |
| Tourette syndrome | Turetto shōkōgun | トゥレット症候群 |



**【おねがい】パンフレットについてのアンケート**

このパンフレットがどのような人に使われているのかを知り、もっと良いパンフレットにするためにアンケートをとっています。

下の URL か、QRコードからアンケートページに入ってください。ご協力をおねがいします。

**【保護者・家族向け】**※やさしいにほんご
https://forms.gle/Tyzy5MDCe7WYPkje8

**【支援者向け】**
https://forms.gle/TS8Ao5YL49sYpEeQ7


**【បោះពុម្ពផ្សាយដោយ】**
មជ្ឈមណ្ឌលជាតិស្តារកាយនីតិសម្បទាជនពិការ ផ្នែកផែនការនិងព័ត៌មាន
មជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់
**អាស័យដ្ឋាន** 〒359-8555 4,1 Namiki, Tokorozawa-shi, Saitama-ken
H/P **http://www.rehab.go.jp/ddis/**

【ត្រួតពិនិត្យ】 Takahashi Osamu (ប្រធានក្រុមហ៊ុនសាជីវកម្មសុខុមាលភាពក្រុង Toyota)
【ស្ថាប័នសហប្រតិបត្តិការ】 មជ្ឈមណ្ឌលស្តីពីការលូតលាស់របស់កុមារក្រុង Toyota ផ្នែកព្យាបាលថែទាំនៃតំបន់

【ចងក្រង-ផលិត】
“អនុគណៈកម្មការបង្កើតសៀវភៅ ជាអាទិ៍ ស្តីពីជំនួយចំពោះកុមារមានវិបត្តិក្នុងការលូតលាស់ ជាពហុភាសា”
(គណៈកម្មាធិការវិភាគព័ត៌មានស្តីពីវិបត្តិក្នុងការលូតលាស់)
【កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ】 ខែមីនា ឆ្នាំ 2022



《ស្តីពីការប្រើសៀវភៅនេះ》

ជាគោលការណ៍ ការបោះពុម្ពផ្សាយនិងចែកចាយសៀវភៅនេះ គឺមិនយកកម្រៃទេ។ រដ្ឋបាលមូលដ្ឋាន ជាអាទិ៍ ដែលចង់ប្រើ សូមជូនដំណឹងមកមជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់យើងខ្ញុំនេះ។

លើសពីនេះ ស្តីពីខ្លឹមសារនៃសៀវភៅនេះ មិនអាចកែដោយគ្មានការអនុញ្ញាតពីមជ្ឈមណ្ឌលព័ត៌មាននិងជំនួយសម្រាប់អ្នកមានវិបត្តិក្នុងការលូតលាស់យើងខ្ញុំនេះបានឡើយ។